# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...០៨...សសរ...

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារ ទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា-វៀតណាម-ឡាវ-ថៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា វៀតណាម – ឡាវ – ថៃដែលមានសមាសភាពដូចតទៅ :-

១-ឯកឧត្តម **ម៉ិន ហ៊ាន** អគ្គនាយកកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹកនិងឧតុនិយម ប្រធាន

២-លោក **ហួន សារឿន** អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាតំណាងគណៈកម្មាធិការចំរុះកិច្ចការព្រំដែន អនុប្រធាន

៣-លោក **កែវ តន្ត្រី** អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤-លោក **គីម ភារុទ្ធី** នាយក នៃនាយកដ្ឋានផ្លូវទឹក ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៥-លោក **ហួយ គីមឡុន** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៦-លោក **ពេជ ឌុន** ប្រធាននាយកដ្ឋានគំរោង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក

៧-លោក **មាស សុផល** អនុប្រធាននាយកដ្ឋានការពារអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន សមាជិក

៨-លោក **គិត សេខ** អនុប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៩-លោក **នូ នីម** នាយអគ្គលេខាធិការដ្ឋានសាលាខេត្តកណ្តាល សមាជិក

១០-លោក **ស៊ុយ ស៊ីថុន** ប្រធានការិយាល័យធារាសាស្ត្រ នាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ២ :** គណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយនៅតំបន់ព្រំដែនកម្ពុជា-វៀតណាម ឡាវ-ថៃមានភារកិច្ចដូចតទៅ :-

ក-ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែង នូវបញ្ហាចោទមុខបច្ចុប្បន្ន អំពីផលប៉ះពាល់ដល់បរិស្ថានសង្គម ធម្មជាតិ នៅតំបន់ព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កឡើងអំពីការលើកទំនប់ និងជីកប្រឡាយរបស់ភាគីវៀតណាម ដោយផ្អែកលើ ៖-

១-កិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈព្រំដែន រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ២០-៧-១៩៨៣ ត្រង់ប្រការ៨ ចំណុច គ

២-សេចក្តីប្រកាសពតិមានរួមរបស់រដ្ឋាភិបាលទាំងពីរកម្ពុជា-វៀតណាម ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៥ និងបណ្តាឯកសារដទៃទៀតដែលពាក់ព័ន្ធ ។

ខ-ពិភាក្សាជាមួយគណៈកម្មាធិការបច្ចេកទេសវៀតណាម ដោយអោយភាគីនេះ បញ្ជាក់អោយបានច្បាស់លាស់នូវផលប៉ះពាល់ ដូចមានចែងក្នុងចំណុច ក ខាងលើ និងរិះរកវិធានការផ្សេងៗដែលខ្លួនត្រូវប្រកាន់យក ដើម្បីបញ្ចៀសនូវផលប៉ះពាល់ដល់បរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ព្រំដែននៃប្រទេសទាំងពីរ ។

គ-ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងារដាក់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច ។

ឃ-ធ្វើការងារដទៃទៀតដែលមានអត្ថន័យ និងខ្លឹមសារប្រហាក់ប្រហែលគ្នានេះ តាមការប្រគល់ភារកិច្ចដោយប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣** : សមាជិកគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍ សំរបសំរួលការងារទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា វៀតណាម ឡាវ ថៃ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៤** : គណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា វៀតណាម ឡាវ ថៃ មានទីស្នាក់ការនៅក្រសួងធនធានទឹក និងឧតុនិយម និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ.ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ- កាលប្បវត្តិ